

# ពិធីបុណ្យចូលព្រះវស្សា

វស្សានរដូវ ឬរដូវភ្លៀងធ្លាក់ជាពេលាដែលសត្វនិករទាំងឡាយ មិនអាចចាកចេញទៅឆ្ងាយដើម្បីស្វែងរកចំណី ឬប្រកបកិច្ចការងារទាំងឡាយដោយងាយស្រួល។ ម្យ៉ាងការចេញដំណើរទៅឆ្ងាយក្នុងពេលភ្លៀងធ្លាក់ក៏អាចនឹងប្រទះគ្រោះអាសន្នជាយថាហេតុ អាស្រ័យដូចនេះព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិការចូល និងការនៅចាំវស្សាដល់ព្រះភិក្ខុសង្ឃស្របទៅតាមប្រពៃណីនេះ។ ចូលវស្សា ឬនៅចាំវស្សា ជាពុទ្ធសាសនៈវាហារ ដែលសំដៅឲ្យដល់ភិក្ខុឈប់សម្រាកនៅទីកន្លែងណាមួយ (បើទោះមិនមែនជាវត្តក្តី[១]) ដោយមិននិមន្តទៅទីណាឲ្យកន្លងរាត្រីអស់កំណត់វេលា៣ខែ[២]។ ប៉ុន្តែព្រះបញ្ញត្តិនេះលើកលែងក្នុងករណីចាំបាច់មួយចំនួនដូចជា ឪពុកម្តាយ ឬគ្រូបាធ្យាយមានជំងឺធ្ងន់ ឬទទួលមរណៈភាព ឬឧបាសកឧបាសិកានិមន្តទៅសម្តែងព្រះធម៌ជាដើម។[៣] ប៉ុន្តែបើទោះក្នុងករណីនេះក្តី ព្រះភិក្ខុសង្ឃត្រូវតាំងចិត្តថានឹងត្រឡប់មកវិញក្នុងរវាង៧ថ្ងៃ (រូបលេខ១)។[៤]

ជាប្រក្រតី ថ្ងៃចូលព្រះវស្សាក្នុងឆ្នាំដែលមានខែបកតិមាស គឺកំណត់ចូលនៅថ្ងៃ១រោច ខែអាសាឍ និងចេញទៅវិញនៅថ្ងៃ១៥កើត ខែអស្សុជ ប៉ុន្តែបើចូលនៅក្នុងឆ្នាំដែលមានខែអធិកមាស ការចូលព្រះវស្សាគឺនៅថ្ងៃ១រោច ខែទុតិយាសាឍ ចេញទៅវិញនៅថ្ងៃ១៥កើត ខែអស្សុជ។ ក្នុងវេលាចូលកាន់ព្រះវស្សា ព្រះភិក្ខុសង្ឃគ្រប់អង្គក្នុងវត្តអារាមនានានឹងប្រមូលផ្តុំនៅរោងឧបោសថ វេលាម៉ោង៧យប់ ហើយតាំងអធិស្ឋានថា "អាត្មាអញនឹងនៅក្នុងឱវាសនេះអស់កំណត់

---

[១] De, 'Buddhist Ceremonies and Rituals of Burma', 13.
[២] Kariyawasam A. G. S, *Buddhist Ceremonies and Rituals of Sri Lanka*, 24.
[៣] De, 'Buddhist Ceremonies and Rituals of Burma', 14.
[៤] *ពុទ្ធសាសនបណ្ឌិត្យ ១៩៦០:១*

អត្ថបទដោយ៖ មាស សុភាព

៣ខែ"។[៥] ត្រឹមតែសេចក្តីអធិស្ឋានប៉ុណ្ណោះ សម្រេចថាជាកិច្ចចូលព្រះវស្សាហើយ (រូបលេខ២)។

តាំងពីពុទ្ធកាលមក ក្នុងវេលាចាំព្រះវស្សាព្រះភិក្ខុសង្ឃទាំងឡាយតែងបំពេញប្រការ២យ៉ាង ដោយតឹងរ៉ឹង និងម៉ឺងម៉ាត់ជាងពេលវេលាដទៃទៀត។ ប្រការទី១ ហៅថា គន្ថធុរៈ ដែលសំដៅចំពោះការរៀនសូត្រធម៌វិន័យ ក្នុងនោះមានគម្ពីរព្រះត្រៃបិដកជាដើម។ ប្រការទី២ ហៅថា វិបស្សនាធុរៈ គឺសំដៅដល់ការចម្រើនសមណធម៌ ដែលជាធម៌រំងាប់ចិត្តឲ្យស្ងប់ រហូតដល់បានសម្រេចមគ្គផល (រូបលេខ៣)។[៦] អាស្រ័យដល់ការបំពេញកិច្ចធុរៈទាំងពីរនេះរបស់ព្រះសង្ឃ នាំឱ្យឧបាសកឧបាសិកាដែលប្រាថ្នាបុណ្យ មានសេចក្តីជ្រះថ្លាឧបត្ថម្ភផ្គត់ផ្គង់ ដោយបច្ច័យផ្សេងៗរួមមាន ចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជៈជាដើម ប្រគេនចំពោះព្រះសង្ឃ ដើម្បីសម្រួលការព្រួយលំបាកទាំងឡាយក្នុងរយៈបំពេញកិច្ចរងចាំព្រះវស្សានេះ។

## ក. ទៀនវស្សា

ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធចូលចាំព្រះវស្សា ពុទ្ធសាសនិកទាំងឡាយបានឧបត្ថម្ភផ្គត់ផ្គង់ព្រះអង្គ ដូចនឹងព្រះសង្ឃគ្រប់អង្គដែរ។ រហូតដល់ព្រះអង្គចូលព្រះនិព្វានទៅ ការបំពេញកិច្ចទាំងឡាយ គឺធ្វើតាមពុទ្ធឱវាទ។ ទន្ទឹមនឹងនោះដើម្បីរំលឹកដល់គុណព្រះសម្មាសម្ពុទ្ធ ពុទ្ធសាសនិកបានថ្វាយគ្រឿងសក្ការៈទាំងឡាយ មានទៀន ធូប ផ្កាភ្ញីជាដើម។ អាស្រ័យដល់ហេតុនេះ ទើបនៅរដូវចូលព្រះវស្សា តែងមានសិតទៀនវស្សាថ្វាយជាសក្ការៈដល់ព្រះរតនត្រ័យ។ ការសិតទៀនវស្សា ជាកិច្ចដែលរាល់ពុទ្ធសាសនិកទាំងឡាយអាចធ្វើបាន ដូច្នេះគឺរួមទាំងប្រជានុរាស្ត្រ និងព្រះមហាក្សត្រ។ ដោយឡែកសូមលើកបង្ហាញកិច្ចរបស់ព្រះមហាក្សត្រក្នុងការសិតទៀនវស្សា។

## ខ. សិតទៀនវស្សា

ការសិតទៀនវស្សានៅក្នុងព្រះបរមរាជវាំង សម្រាប់ឆ្នាំដែលមានខែ១២ធម្មតា គឺធ្វើនៅថ្ងៃ៨កើត ខែអាសាធ ប៉ុន្តែប្រសិនបើឆ្នាំណាមាន១៣ខែ (លើកខែ ដែលមានខែអាសាធ២ដង គឺបឋមាសាធ និងទុតិយាសាធ) គឺធ្វើនៅថ្ងៃ៨កើត ខែអាសាធទី២ វេលាម៉ោង៦ល្ងាច។

ការសិតទៀនវស្សា គឺយកក្រមួនទៅស្ងោរឲ្យរលាយរាវជាទឹក ហើយចាក់ពុម្ពធ្វើជាទៀន។ ចំពោះទីដែលត្រូវស្ងោរក្រមួន គឺនៅក្រៅព្រះទីនាំងទេវាវិនិច្ឆ័យ។ ក្រោយពីក្រមួនស្ងោររលាយសព្វរួចហើយ គេដួសទឹកក្រមួនថ្វាយ

[៥] ពុទ្ធសាសនបណ្ឌិត្យ ១៩៦០:២

[៦] Kariyawasam A. G. S, *Buddhist Ceremonies and Rituals of Sri Lanka*, 24.

អត្ថបទដោយ៖ មាស សុភាព

ទៅព្រះមហាក្សត្រដើម្បីចាក់ទៅក្នុងពុម្ព ដែលត្រៀមរួចជាស្រេចក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ចំពោះមុខស្វេតឆត្រ (រូបភាពទី២)។

## គ. ខ្នាតទៀនវស្សា

តាមប្រពៃណីក្នុងព្រះបរមរាជវាំង ទៀនវស្សាមានពីរខ្នាត ដែលខ្នាតតូច មានទំហំ២ចាប់ ខ្នាតធំមានទំហំ២ចាប់ កន្ទះ ហើយមានកំពស់២ហត្ថដូចគ្នា។ ក្នុងនោះ អំបោះបញ្ចោះទៀនមានចំនួន២០ ទៅ៣០សរសៃ។ កាលពីសម័យមុន ពិសេសក្នុងរាជព្រះបាទស៊ីសុវត្ថិមុនីវង្ស ទៀនវស្សាទាំងមូលធ្វើពីក្រមួនសុទ្ធ លុះក្នុងរជ្ជកាលក្រោយមក ទៀនវស្សាទាំងមូលមិនបានធ្វើដោយក្រមួនសុទ្ធនោះទេ។[៧] ការផ្លាស់ប្តូរនេះ ក៏ឃើញស្របគ្នានឹងការផ្លាស់ប្តូររបស់ប្រទេសកាន់ព្រះពុទ្ធសាសនាជិតខាងផងដែរ។[៨] ទន្ទឹមនឹងនោះ ដើម្បីអុជទៀនឲ្យបានចំណេញ ហើយគ្រប់រយៈពេល៣ខែដែលបានកំណត់ ក្នុងសម័យមុន គេអុជទៀនលាយជាមួយប្រេងដូង ឬប្រេងសណ្តែក។ ធ្វើឲ្យយ៉ាងណាឲ្យប្រេង និងក្រមួននៅពេញប្រៀបស្មើមាត់ពុម្ពជានិច្ច។

## ឃ. វណ្តាប់បរិក្ខារទៀនវស្សា

ទៀនវស្សាមួយៗ តែងមានផ្កាពុម្ព ផ្កាក្រមួន ដោយមែកឈើ ប្រេងដូង ឬប្រេងសណ្តែក ប្រេងកាត ទៀន ធូប ស្លា បារី ជាបរិក្ខារ។[៩] គ្រឿងបរិក្ខាររបស់ទៀនវស្សាអាចមានចំនួនតិចឬច្រើន គឺអាស្រ័យទៅលើទីតាំងដែលដាក់ទៀនវស្សានោះ។ ប្រសិនបើទៀនវស្សានោះ នឹងត្រូវដាក់នៅវត្តអារាម គឺបរិក្ខារទៀនវស្សាមានចំនួន និងប្រភេទដូចរៀបរាប់ខាងដើម។ ដោយឡែក ប្រសិនបើទៀនវស្សានោះ មិនដាក់នៅវត្តអារាមទេ គ្រឿងបរិក្ខារ មិនចាំបាច់មានស្លាបារីនោះឡើយ។ ដោយឡែកសម្រាប់ការប្រតិបត្តិរបស់ប្រជារាស្ត្រវិញ ត្រង់ចំណុចនេះគេនឹងប្រគេនសំពត់សាដក ដល់ព្រះសង្ឃផង គឺប្រគេនជាមួយគ្នានឹងការប្រគេនទានវស្សា។

## ង. ពិធីហែទៀនវស្សា

ក្រោយការសិតទៀនវស្សាបានមួយអាទិត្យ ព្រះមហាក្សត្រព្រះអង្គ ទទួលទៀន និងគ្រឿងបរិក្ខារទៀនវស្សា ហើយធ្វើសេចក្តីអធិដ្ឋានថ្វាយទៀន និងគ្រឿងបរិក្ខារនោះ ចំពោះព្រះរតនត្រ័យ ហើយធ្វើសេចក្តីបួងសួង។ បន្ទាប់មក ទៀនវស្សានឹងហែរទៅតម្កល់នៅទីតាំងដែលបានកំណត់។ ការហែ

---

[៧] ពុទ្ធសាសនបណ្ឌិត្យ ១៩៦០:៧

[៨] Christopher, 'EVOLUTION OF CREATION BUDDHIST LENT CANDLE OF WORK AWARDED IN UBON RATCHATHANI'S LENT CANDLE CONTESTS 2003-2007', 1825.

[៩] ពុទ្ធសាសនបណ្ឌិត្យ ១៩៦០:១៣

អត្ថបទដោយ៖ មាស សុភាព

ទៀនវស្សាជាពិធីតូចល្មម ដោយមានប្រើរថយន្ត និងថ្មើរជើងផង អាស្រ័យលើទីតាំងជិតឬឆ្ងាយ។ ក្នុងពេលបច្ចុប្បន្នការហែទៀនវស្សាមានសភាពធម្មតា ឬអធិកអធមអាស្រ័យនឹងធនធានរបស់ពុទ្ធសាសនិក ប្រការនេះមិនបានបញ្ញត្តិដោយព្រះសម្មាសម្ពុទ្ធនោះទេ (រូបភាពទី៥-៦)។

### ច. ការអុជទៀនវស្សា

ក្រោយថ្ងៃហែទៀនវស្សាមួយថ្ងៃ គឺថ្ងៃ១៥កើត ខែអាសាឍ ដល់ថ្ងៃ១រោច ខែអាសាឍ វេលាម៉ោង៦ល្ងាចមុនព្រះសង្ឃអធិដ្ឋានចូលវស្សា គេនឹងអុជទៀនវស្សា។ ជាទូទៅមុនអុជទៀនវស្សាគឺ តែងមានពិធីនមស្ការព្រះរតនត្រ័យ។ តាមប្រពៃណី ព្រះមហាក្សត្រព្រះអង្គនឹងអុជទៀនវស្សាដោយអង្គឯង ប៉ុន្តែក្នុងករណី ឬទីតាំងខ្លះ ព្រះមហាក្សត្រទ្រង់រាជានុញ្ញាតិឲ្យនរណាម្នាក់តំណាងព្រះអង្គដើម្បីអុជទៀន។ សម្រាប់ក្នុងឱកាសផ្សេងទៀត ព្រះភិក្ខុសង្ឃនឹងអុជទៀនវស្សាចូលកាន់ព្រះវស្សា។

### ឆ. ទំនៀមប្រតិបត្តិចំពោះទៀនវស្សា

ក្នុងសម័យបច្ចុប្បន្ន ទៀនវស្សានីមួយៗក្រោយពីផុតហើយមិនមានត្រណមអ្វីពិសេសនោះទេ ប៉ុន្តែនៅសម័យបុរាណមានត្រណមខ្លាំងណាស់។ ទៀនវស្សាត្រូវមើលថែទាំការពារជាដរាបគ្រប់៣ខែ មិនឲ្យរលត់នោះទេ។ ប្រសិនបើទៀននោះរលត់ គេជឿថានឹងដាច់វស្សា។[១០] ផ្ទុយទៅវិញ តាមបញ្ញត្តិព្រះសម្មាសម្ពុទ្ធ ការដាច់វស្សារបស់ព្រះភិក្ខុសង្ឃ គឺលុះតែព្រះអង្គធ្វើខុសនឹងបញ្ញត្តិព្រះពុទ្ធ មិនមែនដាច់ដោយសារទៀនរលត់នោះទេ។

[១០] ពុទ្ធសាសនបណ្ឌិត្យ ១៩៦០:២០

អត្ថបទដោយ៖ មាស សុភាព



រូបលេខ២ កិច្ចអធិដ្ឋានរបស់ព្រះភិក្ខុសង្ឃ



រូបលេខ៣ ព្រះភិក្ខុសង្ឃធ្វើកិច្ចប្រតិបត្តិ និងរៀនសូត្រព្រះធម៌ក្នុងឱវាស

អត្ថបទដោយ៖ មាស សុភាព



រូបលេខ២៤ ព្រះរាជពិធីសិតទៀនវស្សា (រូបថត: royalducambodge)



រូបលេខ២៥ ក្បួនដង្ហែរទានវស្សា

អត្ថបទដោយ៖ មាស សុភាព



រូបលេខ៦ កិច្ចប្រគេនទានវស្សាដល់ព្រះសង្ឃ

## ឯកសារយោង

ពុទ្ធសាសនបណ្ឌិត្យ

១៩៦០, ព្រះរាជពិធីទ្វាទសមាស ភាគទី៣, ភ្នំពេញ

De, Manikuntala.
1992, 'Buddhist Ceremonies and Rituals of Burma'.

Christopher. 'EVOLUTION OF CREATION BUDDHIST LENT CANDLE OF WORK AWARDED IN UBON RATCHATHANI'S LENT CANDLE CONTESTS 2003-2007'. *American Journal of Applied Sciences* 9, no. 11 (1 November 2012): 1824–27. https://doi.org/10.3844/ajassp.2012.1824.1827.

Kariyawasam A.G.S.
1995, *Buddhist Ceremonies and Rituals of Sri Lanka.* Kandy: Buddhist Publication Society.

អត្ថបទដោយ៖ មាស សុភាព